ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៦៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៦.៥២៥ហិកតា ក្នុងដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៧៣អនក្រ. បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៦.៥២៥ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

សម្រេច

មាត្រា១.-

ត្រូវធ្វើវិសោធនកម្មអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១០ ក្នុងមាត្រា១ នៅបន្ទាត់ទី២ ត្រូវបានកែសម្រួលពី «ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ» មកជា: «ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ និងស្រុកកែវសីមា ខេត្តមណ្ឌលគិរី» វិញ ដែលមានខ្លឹមសារ នៃមាត្រា១ ដូចខាងក្រោម:

«ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.៥២៥ហិកតាក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ និងស្រុកកែវសីមា ខេត្តមណ្ឌលគិរី ក្រោមល័ក្ខខ័ណ្ឌជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ ខ្លឹមចន្ទន៍ ដូចមានក្នុងផែនទី និងនិយាមកា ជាឯកសារលេខ ១២៤៩ សជណ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៩ និងលិខិតលេខ ១៣១០ សជណ.កស ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ»។

មាត្រា២.-

ខ្លឹមសារនៃមាត្រាដទៃផ្សេងទៀត របស់អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៦.៥២៥ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ នៅតែមានសុពលភាពជាគតិយុត្តដដែល។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ